# ការអនុវត្តន៍ល្អ

## បច្ចេកទេសលាតក្រណាត់

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

ផលិតកម្មសំលៀកបំពាក់មានប្រសិទ្ធិភាព និងគុណភាពខ្ពស់ ផ្តើមចេញពីបច្ចេលទេសល្អនៃការលាតក្រណាត់ ។ ជំហ៊ានការងារសាមញ្ញមួយចំនួន អាចឈានឆ្ពោះទៅរកការសន្សំសំចៃលើការចំណាយថ្លៃដើមរបស់រោងចក្រ និងលើកស្ទួយដល់គុណភាពផលិតផលសំរេច ។ បច្ចេកទេសលាតក្រណាត់អន់ខ្សោយ ឬមិនត្រឹមត្រូវ បណ្តាលអោយការចំណាយលើថ្លៃដើមមានកំរិតខ្ពស់ ផលិតកម្មយឺតយ៉ាវ និងគុណភាពផលិតផលសំរេចមានកំរិតទាប ។

### *ការអនុវត្តន៍ល្អសំរាប់ផ្នែកកាត់ក្រណាត់*

នៅពេលលាតក្រណាត់ ធានាយ៉ាងណារយៈចំងាយពីគែមក្រណាត់ មកទល់នឹងគំនូសពុម្ពអោយមានប្រវែង ២ស.ម (រូបភាពទី១) ។

ប្រភេទក្រណាត់នីមួយៗមានជំរៅស្រទាប់ដែលត្រូវលាតខុសៗគ្នា ។ រៀបចំ និងដាក់បង្ហាញតារាងជំរៅស្រទាប់ក្រណាត់ ដើម្បីអោយកម្មករបានដឹង ពីជំរៅរបស់វា (រូបភាពទី២) ។

នៅពេលលាត ចូរពិនិត្យទ្រង់ទ្រាយរបស់ក្រណាត់ ដោយប្រើប្រាស់ម្ពុលវែង ដោតលើវាដើម្បីធានាអោយការលាតក្រណាត់មានភាពត្រង់ជួរ ។ (រូបភាពទី៣ បង្ហាញពីបច្ចេកទេសលាតសំរាប់ប្រភេទក្រណាត់ឆ្នូតដែលមិនត្រឹមត្រូវ) ។

ប្រើប្រាស់អង្គុំដែលអាចស៊ីរ៉េជំរៅបាន ដើម្បីរក្សាកុំអោយក្រណាត់រំកិលនៅពេលកាត់ (រូបភាពទី៤) ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣


រូបភាពទី៤

### អត្ថប្រយោជន៍:

- ✓ ធ្វើអោយគុណភាពការងារប្រសើរឡើង
- ✓ ធ្វើអោយផលិតភាពប្រសើរឡើង
- ✓ បង្កើនសុក្រិតភាពនៃការកាត់
- ✓ កាត់បន្ថយកំហុស និងកាកសំណល់

### តាមរបៀបណា:

- ✓ បុគ្គលិករោងចក្រអាចរៀបចំតារាងជំរៅស្រទាប់ក្រណាត់បាន
- ✓ អង្គុំអាចរកទិញបានក្នុងទីផ្សារពាណិជ្ជកម្ម
- ✓ ផ្តល់ការបណ្តុះបណ្តាលជាប្រចាំដល់កម្មករដើម្បីបង្រៀនគេពីបច្ចេកទេសល្អ នៃការលាតក្រណាត់

### តំលៃ:

$

- $ តំលៃទាប
- $$ តំលៃមធ្យម
- $$$ តំលៃខ្ពស់

អង្គការ
ពលកម្ម
អន្តរជាតិ

ប្រសិនបើលោកអ្នកមានសំនួរ សូមទាក់ទងមកអង្គការពលកម្មអន្តរជាតិតាមរយៈអ៊ីម៉ែល betterfactories@ilo.org